## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀងស្តីពីការព្យួរកិច្ចសន្យាការងារ រវាងក្រុមហ៊ុនសិប្បករអង្គរ និងប្រតិភូបុគ្គលិក
## ("កិច្ចព្រមព្រៀង")
### ស្របតាមបញ្ញត្តិមាត្រា ៧១ និង៧២ នៃច្បាប់ស្តីពីការងារ

កិច្ចព្រមព្រៀងនេះ ត្រូវបានធ្វើឡើងរវាងបណ្តាភាគីដូចខាងក្រោម៖

(១) ក្រុមហ៊ុន **សិប្បករអង្គរ** ជាក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកម្រិត ដែលបានចុះបញ្ជីត្រឹមត្រូវនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានលេខចុះបញ្ជីពាណិជ្ជកម្ម Co.១៧១១E/២០០៣ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០៣ មានអាសយដ្ឋានចុះបញ្ជីស្ថិតនៅផ្លូវស្ទឹងថ្មី ខេត្តសៀមរាប ព្រះរាជាណាចក្រកម្ពុជា តំណាងដោយ **ឯកឧត្តម សុខ សង្វារ** មានតួនាទីជា **ប្រធានក្រុមប្រឹក្សាភិបាល** របស់ក្រុមហ៊ុន (តទៅហៅថា"ក្រុមហ៊ុន") និង

(២) ប្រតិភូបុគ្គលិកទាំងអស់របស់ក្រុមហ៊ុន ដែលជាតំណាងស្របច្បាប់របស់កម្មករនិយោជិតទាំងអស់នៅក្នុងក្រុមហ៊ុន រួមទាំងកម្មករនិយោជិតទាំងឡាយដែលត្រូវព្យួរកិច្ចសន្យាការងារ (ដូចមានរាយនាមនៅក្នុងបញ្ជីតារាងដែលភ្ជាប់មកជាមួយនឹងកិច្ចព្រមព្រៀងនេះ) (តទៅហៅថា "ប្រតិភូបុគ្គលិក")។

កិច្ចព្រមព្រៀងនេះ គឺត្រូវបានធ្វើឡើងដើម្បីបញ្ជាក់ឡើងវិញនូវលទ្ធផលនៃកិច្ចពិភាក្សា និងការព្រមព្រៀងគ្នា រវាងក្រុមហ៊ុន និងប្រតិភូបុគ្គលិក នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២០ និងនៅថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ២០២០ ពាក់ព័ន្ធនឹងការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតនៃក្រុមហ៊ុន ដូចបានកំណត់ខាងក្រោមនេះ៖

### ចំណុចទី ១៖ ការព្យួរកិច្ចសន្យាការងារ

ដោយសារផលប៉ះពាល់ផ្នែកហិរញ្ញវត្ថុដ៏ធ្ងន់ធ្ងរចំពោះក្រុមហ៊ុន ដែលកើតឡើងដោយសារវិបត្តិជំងឺកូវីដ-១៩ ដែលមិនធ្លាប់កើតមានពីពេលមុនមក កិច្ចសន្យាការងាររបស់កម្មករនិយោជិត ចំនួន ១០ នាក់ របស់ក្រុមហ៊ុន ("**កម្មករនិយោជិតដែលត្រូវព្យួរកិច្ចសន្យាការងារ**") ដូចមានរាយនាមនៅក្នុងបញ្ជីតារាងដែលភ្ជាប់ជាមួយនឹងកិច្ចព្រមព្រៀងនេះ (ដែលក្នុងនោះ មានកម្មករនិយោជិតជាស្ត្រី ចំនួន ០៧ នាក់) នឹងត្រូវបានព្យួរនៅក្នុងចំណោមកម្មករនិយោជិតទាំងអស់របស់ក្រុមហ៊ុន ចំនួន ១០ នាក់ (ដែលក្នុងនោះ មានកម្មករនិយោជិតជាស្ត្រី ចំនួន ០៧ នាក់) សម្រាប់រយៈពេល ០២ ខែ ដោយគិតចាប់ពីថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២០ ("**អំឡុងពេលនៃការព្យួរកិច្ចសន្យាការងារ**") ដែលរយៈពេលនេះអាចនឹងត្រូវបានផ្លាស់ប្តូរអាស្រ័យតាមការផ្លាស់ប្តូរនៃស្ថានភាពជាក់ស្តែង ឬស្ថានភាពជុំវិញនានា។

**ចំណុចទី ២៖ ប្រាក់ឧបត្ថម្ភតាមការស្ម័គ្រចិត្ត ជូនកម្មករនិយោជិតដែលត្រូវព្យួរកិច្ចសន្យាការងារ នៅក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារ**

ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុននឹងផ្តល់ប្រាក់ឧបត្ថម្ភតាមការស្ម័គ្រចិត្ត ជូនកម្មករនិយោជិតម្នាក់ៗ ដែលត្រូវព្យួរកិច្ចសន្យាការងារ ចំនួន ៣០ ដុល្លារអាមេរិក ក្នុងមួយខែ ("ប្រាក់ឧបត្ថម្ភសម្រាប់ការព្យួរកិច្ចសន្យាការងារ")។ ប្រាក់ឧបត្ថម្ភសម្រាប់ការព្យួរកិច្ចសន្យាការងារនេះ នឹងផ្តល់ជូនកម្មករនិយោជិតម្នាក់ៗ ដែលត្រូវព្យួរកិច្ចសន្យាការងារ នៅថ្ងៃចុងក្រោយនៃខែនីមួយៗ តាមរយៈការផ្ទេរតាមគណនីធនាគារទៅកាន់គណនីធនាគារដែលបានកំណត់ជាស្រេចរបស់កម្មករនិយោជិតនោះ។

**ចំណុចទី ៣៖ ទំនាក់ទំនងការងាររវាងក្រុមហ៊ុន និងកម្មករនិយោជិតដែលត្រូវព្យួរកិច្ចសន្យាការងារ នៅក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារ**

នៅក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតដែលត្រូវព្យួរកិច្ចសន្យាការងារមិនត្រូវធ្វើការជូនក្រុមហ៊ុននោះឡើយ។ ដើម្បីជម្រះនូវមន្ទិលសង្ស័យ ក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតដែលត្រូវព្យួរកិច្ចសន្យាការងារ នៅតែមានកាតព្វកិច្ចគោរពតាមបញ្ញត្តិស្តីពីការហាមឃាត់ ឬការរឹតត្បិតនានា (ដូចជាកាតព្វកិច្ចទាក់ទងនឹងការរក្សាភាពស្មោះត្រង់ និងការរក្សាការសម្ងាត់ចំពោះក្រុមហ៊ុន) ស្របតាមបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធ កិច្ចសន្យាការងាររបស់ពួកគេ និង/ឬ វិធានផ្ទៃក្នុង និងគោលនយោបាយទាំងឡាយរបស់ក្រុមហ៊ុន ហើយកម្មករនិយោជិតទាំងនេះ មិនត្រូវបានអនុញ្ញាតឲ្យមានវត្តមាននៅក្នុងបរិវេណក្រុមហ៊ុន និង/ឬ នៅកន្លែងធ្វើការរបស់ខ្លួន ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរជាមុនពីក្រុមហ៊ុននោះឡើយ។

នៅក្នុងអំឡុងពេលនៃការព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុនមិនត្រូវផ្តល់ជូននូវប្រាក់ឈ្នួល និង/ឬ អត្ថប្រយោជន៍ផ្សេងទៀតជូនកម្មករនិយោជិតដែលត្រូវព្យួរកិច្ចសន្យាការងារនោះឡើយ លើកលែងតែប្រាក់ឧបត្ថម្ភសម្រាប់ការព្យួរកិច្ចសន្យាការងារ ស្របតាមចំណុចទី២ នៃកិច្ចព្រមព្រៀងនេះ។

នៅក្នុងករណីដែលបញ្ហានានាពាក់ព័ន្ធនឹងការព្យួរកិច្ចសន្យាការងារកើតឡើង ដែលមិនត្រូវបានកំណត់នៅក្នុងកិច្ចព្រមព្រៀងនេះ ក្រុមហ៊ុននឹងអនុវត្តតាមបទប្បញ្ញត្តិច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីដោះស្រាយនូវបញ្ហាទាំងនោះ។

ដោយសេចក្តីរាប់អានអំពីយើងខ្ញុំ
(ហត្ថលេខា និងត្រា)

សិប្បករអង្គរ
SEPAKOR ANGKOR
Co.,Ltd.

**ឯកឧត្តម សុខ សទ្ធារ**
តួនាទី៖ **ប្រធានក្រុមប្រឹក្សាភិបាល**
កាលបរិច្ឆេទ៖ ថ្ងៃទី ...០៣... ខែ ..មេសា... ឆ្នាំ២០២០

យើងខ្ញុំជាប្រតិភូបុគ្គលិករបស់ក្រុមហ៊ុន តាមរយៈនេះ សូមបញ្ជាក់ទទួលស្គាល់ថាបានទទួលលិខិតជូនដំណឹងនេះ ហើយបញ្ជាក់ទទួលយក និងយល់ស្រប ចំពោះខ្លឹមសារនៃលិខិតជូនដំណឹងនេះ នៅថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០២០។

(ហត្ថលេខា និងស្នាមផ្តិតមេដៃ)
លោក ទត ម៉ានីហ្សរីត
តួនាទី៖ អនុប្រធានហាងភ្នំពេញ

(ហត្ថលេខា និងស្នាមផ្តិតមេដៃ)
លោក អ៊ិន ប៊ុនធូ
តួនាទី៖ បុគ្គលិកផ្នែកលក់